រឿង

# ក្តាន់ ក្អែក អណ្តើក ជាសម្លាញ់



ក្អាន់ ក្អែក អណ្តើកជាសម្លាញ់

រៀបរៀងដោយលោក វ៉ា សំអាត

គូររូបដោយលោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)

បោះពុម្ពឆ្នាំ២០០៧

# រឿង ក្តាន់ ក្អែក អណ្តើកជាសម្លាញ់





ក្តាន់ ក្អែក និងអណ្តើក សត្វទាំងបីនេះជាសម្លាញ់នឹងគ្នា តែងពឹងពាក់គ្នាទៅវិញទៅមក ។ ថ្ងៃមួយ ក្តាន់ចេញទៅរកស៊ីតែម្នាក់ឯង ក៏ជាប់អន្ទាក់ព្រានព្រៃ ។





ដោយថ្ងៃនោះបាត់មិនឃើញក្ដាន់មក ក្អែក និងអណ្ដើកនាំគ្នាចេញទៅរក ។ ពួកគេបានឃើញក្ដាន់ជាប់អន្ទាក់ ក៏បន្ទោសថា "សម្លាញ់! ហេតុអ្វីក៏ឯងដើររកស៊ីមិនប្រុងប្រយ័ត្ននាំឱ្យជាប់អន្ទាក់គេយ៉ាងនេះ?" ក្ដាន់និយាយថា "ឱ សម្លាញ់អើយ! ខ្ញុំបានជាខុសទៅហើយ សូមឯងទាំងពីរជួយគិតដោះទុក្ខខ្ញុំផង" ។





ក្អែកក៏ហើរទៅពាំទឹកមកស្រោចខ្សែអន្ទាក់ឱ្យទន់ ។





ឯអណ្ដើកខំប្រឹងកកេរខ្សែអន្ទាក់នោះ តាំងពីពេលប់រហូតដល់ភ្លឺ ។ វាកាត់ខ្សែបានពីរធ្លុង នៅសល់តែមួយធ្លុង ។ ជួនពេលនោះ អណ្ដើក និងក្អែកឃើញព្រានដើរមកពីចម្ងាយ ក៏ប្រាប់ក្ដាន់ថា "សម្លាញ់អើយ! ពេលនេះ ម្ចាស់អន្ទាក់មកជិតដល់ហើយ ចូរឯងប្រមូលកម្លាំង ដើម្បីបោលកន្ត្រាក់អន្ទាក់ឱ្យដាច់ដោយខ្លួនឯងចុះ" ។ ប្រាប់ហើយ អណ្ដើក និងក្អែកក៏គេចទៅពួនក្នុងព្រៃចាំលបមើល ។





កាលបើព្រានមកដល់   ក្តាន់ក៏ស្ទុះបោលអស់ទំហឹងកន្ត្រាក់ផ្តាច់ខ្សែអន្ទាក់នោះបាន ហើយបោលចូលព្រៃទៅ ។





នាយព្រាននឹកស្ដាយក្ដាន់ណាស់   ខំប្រឹងដេញតាម  ទៅប្រទះ
ឯអណ្ដើកដែលកំពុងពួន   ក៏ចាប់អណ្ដើកនោះ   ហើយវិលមកដាក់
អន្ទាក់ម្ដងទៀត ។





ឃើញព្រានចាប់អណ្ដើកជាសម្លាញ់ ក្អែកក៏ទៅនិយាយនឹងក្ដាន់ថា "សូមសម្លាញ់ធ្វើពុតជាបាក់ជើង ហើយដើរកាត់ពីមុខនាយព្រាន ។ បើព្រាននោះឃើញឯង គាត់គង់នឹងចោលអណ្ដើក រត់ដេញសម្លាញ់ឯងជាមិនខានឡើយ ។ សម្លាញ់ត្រូវតែរត់គេចមកខាងក្រោយវិញ ហើយខាំពាំអណ្ដើកគេចចូលព្រៃទៅ " ។





ក្ដាន់ក៏ធ្វើតាមគំនិតរបស់ក្អែក ។ ឯនាយព្រាននឹកស្មានថាក្ដាន់នោះបាក់ជើងដោយអន្ទាក់វាត់ពិតមែន ក៏រត់ដេញតាមក្ដាន់ភ្លាម ។





ក្ងាន់បែរមកឃើញព្រានមិនទាន់ដាក់អណ្ដើកចុះ   ក៏ធ្វើពុតជាបោលតិចៗ ។ ព្រានយល់ថាអណ្ដើកជាសត្វតូច  សាច់តិចមិនមានប្រយោជន៏ជាងក្ងាន់ជាសត្វធំដែលមានសាច់ច្រើនឡើយ   ក៏ទម្លាក់អណ្ដើកចុះលើគុម្ពស្បូវ ហើយរត់ដេញក្ងាន់ទៀតទៅ ។





ក្ដាន់ដឹងថា នាយព្រានចោលអណ្ដើកហើយ ក៏ធ្វើជាបោលជន្លនាយព្រានឱ្យដេញចេញផុតពីព្រៃស្បូវ ។ លុះបានឱកាសហើយ ក្ដាន់ក៏បោលគេចមកក្រោយ ហើយពាំអណ្ដើកជាសម្លាញ់បោលចូលព្រៃបាត់ទៅ ។

ៜៜៜ ចប់ ៜៜៜ



